# អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍
# Action for Research and Development

សមត្ថភាព គុណភាព តម្លាភាព
Capacity Quality Transparency

ផ្ទះលេខ ៥១F ផ្លូវ ២៦៥ សង្កាត់ ទឹកល្អក់ ៣
ខណ្ឌទួលគោក ក្រុងភ្នំពេញ កម្ពុជា
ទូរសព្ទ័លេខ: ០១៦ ៧៧៨ ៧០១
អ៊ីម៉ែល: ard.cambodia@yahoo.com
ard.info@yahoo.com
ប្រអប់សំបុត្រ: CCC ៣០៤

# ពត៌មានសំខាន់សំរាប់អ្នក
# Necessary News for You

## ព្រឹត្តិបត្រពត៌មានប្រចាំខែ
## Monthly Newsletter

### មាតិកាពត៌មាន

- ស្ថានភាពការប្រើប្រាស់ថ្នាំពុលកសិកម្មលើដំណាំបន្លែរបស់កសិករនៅឃុំឬស្សីស្រុក... ២
- ដំណឹងជ្រើសរើសបុគ្គលិក........................................... ៣
- ករណីសិក្សា ស្តីអំពីការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារតាមគោលការណ៍ធម្មជាតិ..... ៥
- បន្លែបង្ការ ដីសើម និងសំរាមៈ ការធានាសុវត្ថិភាពស្បៀងនៅភ្នំពេញ.......... ៧
- អង្គការលើកលែងទោសអន្តរជាតិរិះគន់ការបណ្តេញចេញពីដីនៅក្រុងព្រះសីហនុ..... ៨
- សាលាក្តីកាត់ទោសក្រុមមេដឹកនាំខ្មែរក្រហម ឆ្ពោះទៅមុខសន្សឹមៗ.............. ៩
- សូមបោះឆ្នោតជូនប្រាសាទអង្គរវត្ត ជាអច្ឆរិយទាំង៧ក្នុងពិភពលោក.............. ១០

ចែកជូនដោយឥតគិតថ្លៃ

**ពត៌មានសំខាន់សំរាប់អ្នក** រៀបចំ និងបោះពុម្ពដោយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ (ARD)

# កម្មវិធីរបស់ ARD

## ស្ថានភាពការប្រើប្រាស់ថ្នាំពុល កសិកម្មទៅលើដំណាំបន្លែ របស់ កសិករនៅឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

ក្រុមបុគ្គលិកអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានធ្វើដំណើរទស្សនៈកិច្ចមួយដើម្បីសិក្សាស្វែងយល់ពីស្ថានភាព នៃការប្រើប្រាស់ថ្នាំពុលទៅលើដំណាំបន្លែរបស់កសិករនៅឃុំឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ការសិក្សាស្វែងយល់នេះធ្វើឡើងដោយលោក សួន សុខេង នាយកប្រតិបត្តិ និងលោក នេត សុភីរុន ជំនួយការផ្នែកស្រាវជ្រាវរបស់អង្គការអេ អ ឌី ។

ឃុំឫស្សីស្រុក គឺជាឃុំមួយរបស់ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដែលស្ថិតនៅតាមបណ្តោយទន្លេមេគង្គ មានចំងាយប្រហែល៦៥ គីឡូម៉ែត្រភាគខាងកើតរាជធានីភ្នំពេញ ។ ឃុំឫស្សីស្រុក ចែកចេញជា ៤ភូមិ គឺភូមិត្នោតលើ ត្នោតក្រោម ឫស្សីស្រុក និងភូមិព្រៃទទឹង ដែលមានប្រជាជនចំនួន ១៣៤០ គ្រួសារ ត្រូវជា ៥៧០២នាក់ (ស្រី ៣១២០នាក់) ។ ប្រជាជនប្រមាណជាង៨០% ប្រកបរបរធ្វើស្រែ និងចំការ ក្នុងនោះមានចំការសណ្តែក ថ្នាំជក់ ល្ង ពោត និងដំណាំបន្លែគ្រប់មុខ ។

តាមលោកទី ទៀង សមាជិកក្រុមប្រឹក្សាឃុំឫស្សីស្រុក បានអោយដឹងថា សឹងតែគ្រប់កសិករដែលធ្វើស្រែចំការទាំងអស់ គឺតែងតែដាំដុះបន្លែនៅរដូវដែលពួកគាត់ទំនេរដៃ ពីការងារស្រែរបស់ខ្លួន ហើយក្នុងនោះមានកសិករប្រមាណ ១០០ គ្រួសារ ដែលជាកសិករដាំដុះបន្លែ ជាអចិន្រ្តៃយ៍សំរាប់ផ្គត់ផ្គង់ជីវភាព ។ បន្លែដែលកសិករនៅឃុំឫស្សីស្រុកដាំ រួមមាន ត្រសក់ ម្រះ ពពួកស្ពៃ (ស្ពៃក្តោប ផ្កាស្ពៃ ស្ពៃចង្កឹះ...) ខ្ទឹម ម្ទេស សណ្តែកគួរ ប៉េងប៉ោះ... ។ ផលិតផលបន្លែទាំងនេះ ត្រូវបានលក់នៅទីផ្សារក្នុងភូមិ-ឃុំ និងនាំចេញទៅលក់ផងដែរនៅផ្សារទីរួមស្រុក ផ្សារខេត្តកំពង់ចាម និងទីក្រុងភ្នំពេញ ។ លោក ទី ទៀង បានបន្តទៀតថា គ្រប់កសិករទាំងអស់បានប្រើប្រាស់ជី និងថ្នាំពុលកសិកម្ម នៅក្នុងការធ្វើស្រែចំការ និងដំណាំបន្លែ ដើម្បីការពារពីការបំផ្លាញពីសត្វល្អិត និងជំងឺរាតត្បាតលើដំណាំ ។ មិនត្រឹមតែឃុំរបស់លោកតែមួយប៉ុណ្ណោះទេ ដែលជួបប្រទះបញ្ហានេះ ប៉ុន្តែឃុំដែលជាប់គ្នានេះ គឺឃុំស្វាយសាច់ភ្នំ ឃុំព្រៃកំដេង ឃុំបារាយ និងឃុំព្រៃដំបូក ក៏មានការប្រើប្រាស់ថ្នាំពុលយ៉ាងខ្លាំងក្លាផងដែរ ។ នៅរៀងរាល់ឆ្នាំ ក្រុមប្រឹក្សាឃុំឫស្សីស្រុក តែងតែលើកនូវគំរោងផ្សព្វផ្សាយពីការប្រើប្រាស់ និងផលប៉ះពាល់របស់ថ្នាំពុល នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ប៉ុន្តែមិនដែលមានការគាំទ្រពីអង្គការ ឬស្ថាប័នពាក់ព័ន្ធណាមួយឡើយ ។

លោកកែវ ម៉េង ជាកសិករធ្វើស្រែជាអចិន្រ្តៃយ៍ បានមានប្រសាសន៍ថា គ្រួសារគាត់បានប្រើប្រាស់ថ្នាំពុលកសិកម្មទៅលើដំណាំរបស់គាត់ ព្រោះគ្មានវិធីណាអាចជំនួសបានឡើយនៅពេលដែលគាត់ចង់អោយស្រូវ និងដំណាំទទួលបានផលខ្ពស់ ។ ទន្ទឹមនឹងនេះ គាត់ក៏សង្កេតឃើញថាទិន្នផលដំណាំពោតរបស់គាត់សព្វថ្ងៃធ្លាក់ចុះជាគំហុក ដែលក្នុងមួយឆ្នាំទទួលបានតែផលចំនួនប្រហែល១០០-២០០ គីឡូក្រាមប៉ុណ្ណោះ ក្នុងខណៈពេលដែលមុនឆ្នាំ១៩៩៥ គាត់ទទួលបានផលរហូតដល់៨០០គីឡូក្រាម ដែលគាត់ធ្វើនៅលើផ្ទៃដីដូចគ្នានេះ ។

លោកឡាយ អូវ កសិករដាំដុះបន្លែគ្រប់មុខ បានមានប្រសាសន៍ថាគាត់បានប្រើថ្នាំពុលច្រើនណាស់សំរាប់ការលូតលាស់ និងផ្តល់ផលល្អចំពោះបន្លែរបស់គាត់ គាត់មិនដែលបានចូលរួមក្នុងវគ្គផ្សព្វផ្សាយ រឺបណ្តុះបណ្តាលណាមួយស្តីពីផលប៉ះពាល់ថ្នាំពុលនេះទេ ។

លោកអ៊ឹ ណែម រឹម ដែលជាកសិករដាំដុះបន្លែច្រើនមុខដែរនោះក៏បានប្រាប់ផងដែរថា គ្រួសារគាត់ដាំបន្លែដោយជួលដីគេ ព្រោះគ្មានដីកម្មសិទ្ធផ្ទាល់ខ្លួន ។ ការចំណាយទៅលើការជួលដី និងថ្នាំពុលជូនកាលរដូវខ្លះធ្វើអោយគាត់មិនអាចសល់ប្រាក់សំរាប់ផ្គត់ផ្គង់ជីវភាពបានឡើយ ។

***កសិករទាំងអស់ដែលអង្គការ អេ អ ឌី បានជួបសំណេះសំណាល បានសំដែងការរីករាយនៅក្នុងការចូលរួមក្នុងវគ្គផ្សព្វផ្សាយ រឺបណ្តុះបណ្តាលទាក់ទងនឹងផលប៉ះពាល់ថ្នាំពុល ហើយពួកគាត់ថែមទាំងសំ-ណូមពរសូមផ្តល់បច្ចេកទេសថ្មីដល់ពួកគាត់ ដើម្បីអោយគាត់អាចកាត់បន្ថយ រឺជៀសវាងមិនប្រើថ្នាំពុលកសិកម្មផងដែរ ។***

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News

# ដំណឹងជ្រើសរើសបុគ្គលិក

| | |
|---|---|
| **ARD :** | Training of Trainer (TOT) |
| **SOVAN PHOUM:** | Executive Director |
| **UNDP :** | All Positions |
| **CARE :** | Chief of Party |
| **Every Child:** | Finance and Administration Manager |
| **Save the Children Australia:** | Country Director |
| **FAO:** | Animal Health Workers Trainer |
| **VBNK:** | CHART Project Manager |

**Action for Research and Development 'ARD'** is seeking the Trainees for attending a new training course on **Training of Trainer (TOT)** which will take place in the weekends (Saturday and Sunday). The training will start on 19 May 2007 and facilitate by experience Trainers.

The course will cover in the main following topics:

- Adult learning principles
- Training Need Assessment (TNA)
- Training cycle and methodology
  Role of Trainers/Facilitators
- Training Designs
- Monitoring and evaluation of the training process

All students and young graduates from various Universities who interested this subject and **have available time as the date mentioned above** are invited to apply for participating this training course by submission **an updated CV with a current photo and a Letter of Interest** to ARD office: house # 51F, St 265, Teuk Laak3, Tuol Kuok, Phnom Penh. For more information please contact through phone number 016 77 87 01.

**Note:**

- **No any applications by email will received.**
- **The successful candidates have to contribute a small fee for the training course.**

***Deadline: May 18, 2007***

---

**SOVANN PHOUM (SP)** invites qualified Cambodian candidates to apply for the position of **Executive Director.** The skills and qualifications required are Bachelor or master degree of Social Sciences of Management, Proven leadership and fund raising abilities to support SP program, Substantial prior management experience with non-profit organization, Creativity, flexibility and imagination in designing and implementing projects. More detail information lease contact Sovann Phoum office# 48, St 608, Boeung KakII, Tuol Kuok. Tel: 023 883 523

**Closing Date: 31 May 2007**

**United Nation for Development Program:** is seeking to fill the following vacancies for its projects in Phnom Penh as soon as possible.

1. **Green House Gas (GHG) Inventory Advisor**
2. **National Team Leader**
3. **LEAP Management/Operations Advisor**
4. **Project Manager**
5. **Finance Assistant**

**Post 1:** The GHG Inventory Advisor will work in close collaboration with the National Team Leader of the GHG Inventory Thematic Working Group (TWG-1) and its members to ensure the successful production.

**Post 2:** The National Team Leader will have overall responsibility to ensure the successful production by TWG-1.

**Post 3:** The Cambodian parliament has recently approved a strategic framework and action plan to support the modernization of the institution. UNDP has been asked to support this endeavour. A Legislature Assistance Project (LEAP) is about to be launched. The Management/Operations Advisor will assist the newly-established-Technical Coordination Secretariat in formulating, implementing, coordinating and monitoring project activities, draft annual and quarterly reports, budgets, work plans and correspondence, assist in conducting seminars and workshops, etc.

**Post 4:** The project Manager ensure effective management of UNDP Cambodia strengthening Democracy and Electoral Processes in Cambodia, ensuring compliance with appropriate UNDP policies and procedures, and Cambodian Laws and regulations.

**Post 5:** Under the guidance and supervision of the Operations Manger and direct supervisor, the Finance Assistant provides financial services ensuring high quality, accuracy and consistency of work. The finance assistant promotes a client oriented approach consistent with UNDP rules and regulations.

**How to Apply?**

Please send your application letter, CV and completed UN Personal History Form (P11) by email to applications.kh@undp.org, identifying the post title in the subject line.

**Closing Date:**

- **18 May 2007** for Post 1, Post 2, Post 5
- **23 May 2007** for Post 3
- **01 June 2007** for Post 4

# ទំព័រឱកាសសំរាប់អ្នក

# ដំណឹងជ្រើសរើសបុគ្គលិក

## Brief Job News Continue....

**CARE International in Cambodia** is currently recruiting a **Chief of Party** to manage the USAID-funded Strengthened Capacity for Improved Community Health program, an integrated program which aims to improve the health and survival of the people of Cambodia through activities in four focus areas of:

- maternal, newborn and child health and nutrition
- reproductive health and family planning
- HIV/AIDS
- and other infectious diseases, including TB, malaria and dengue.

Selection Criteria:

- Relevant Master's degree e.g. MPH
- At least 7 year of public health overseas experience, 5 in a senior management position, Significant experience of managing large, complex projects or programs, at least 5 year experiences in staff supervision and development.

Detail position description available from CARE Office # 255, Corner Street 63/Mao Tse Tung Blvd, Phnom Penh.

Interested Candidates, **Please submit CV and cover letter explaining suitability for the position. Please mark applications clearly with Ref: USAID/COP/07 and return to Human Resource Department, CARE Cambodia**. Email: hrd@care-cambodia.org

**Closing Date: 16 May 2007**

---

**Every Child** in Cambodia would focus its work on violence (physical, sexual and emotional) against children living and working on the streets (in particular those who are in, or are likely to come into, conflict with the law). We are looking for a Cambodian National to fill the position of **Finance and Administration Manager.** The FAM is responsible for monitoring and evaluating financial, accounting and administrative activities. This post has responsibility for supervising all financial operations within EvC Cambodia and the independent partners with whom EvC Cambodia works, including preparation, implementation and monitoring of the EvC Cambodia annual budget, accounts, internal and donor financial reporting and communication internally and externally with partners and donor.
Qualifications Experience and Competencies are A recognised qualification in accountancy or equivalent, at least 5 years of work experience in financial management, preferable within NGOs.

Please address all applications to: Jojo Pastores, Country Director, Every Child Cambodia 1st floor, VBNK Building, # 28, St 80/75, Sras Chak, Daun Penh. Email: adminofficer@everychildkh.org by **May 14 2007.**

**Save the Children Australia:** is seeking an experienced **Director** to lead the strategic development and delivery of our program of work in Cambodia, to maximize our impact on realizing the rights of vulnerable children and to contribute to our global impact. The person will lead and develop a cross-functional team at country level, build effective relationships, mobilize resources to support our work, and contribute to organizational learning and the achievement of the wider objectives of the organization.
Please forward applications to email: programadmin@savethechildren.org.au

**Applications close by 5.30 pm at 18 May 2007**.

---

**Food and Agriculture Organization of the United Nations:** seeks qualified Cambodian candidates for the position of **'Village Animal Health Workers Trainer'**. This position qualifications: A veterinarian with practical experience in animal health care and community based training and extension activities. He/she will be fluent in the local language with a working knowledge of English (level B).

**Duty station:** Phnom Penh/5days a week in provinces
**Duration:** 7 month
**Deadline:** 11 May 2007

Qualified individual may submit CV with motivation letter to FAO Representative in Cambodia # 5, Street 370, Boeung Keng Kang I or email to FAO-KH@fao.org only short-listed candidates will be notified for interview.

---

**VBNK** is currently seeking a qualified candidate to fill the position of **CHART Project Manager**. The candidate should have strong facilitation skills and management experience, and be able to lead a dynamic team supporting holistic learning processes within themselves; the project, the partners we serve and within VBNK.

All applicants should have a strong understanding of a commitment to gender equity, values and ethics.

*Please send your CV and application form to the Administration Manger to VBNK # 28, Street 80 (near Calmette Hospital) Phnom Penh.*

**Closing Date:** 12 May 2007

# កសិកម្ម និងការអភិវឌ្ឍន៍

## ករណីសិក្សា ស្តីអំពី ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារតាមគោលការធម្មជាតិ

អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានអនុវត្តគំរោងកែលំអការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ នៅភូមិកន្លែងរមាស ឃុំពេជ្រមុនី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយបានជ្រើសរើសកសិករចំនួន ២០ គ្រួសារ ចូលជាក្រុមគោលដៅរបស់គំរោង។ បន្ទាប់ពីការអនុវត្តគំរោងត្រូវបានបញ្ចប់នាខែមីនា ឆ្នាំ ២០០៧ កន្លងទៅនេះ បុគ្គលិកអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានចុះធ្វើការអង្កេត និងសរសេរករណីសិក្សា ដើម្បីបង្ហាញពីលទ្ធផលវិជ្ជាមាន និងការចាប់អារម្មណ៍របស់កសិករគោលដៅ ករណីសិក្សានេះ មានខ្លឹមសារដូចតទៅ :

កសិករឈ្មោះ **វិទ្ធិ ខុន** អាយុ ៤៦ ជាកសិកររស់នៅភូមិកន្លែងរមាស ឃុំពេជ្រមន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដោយមានមុខរបរជាអ្នកធ្វើស្រែ ឡើងត្នោត និងចិញ្ចឹមសត្វបន្ទាប់បន្សំ។ គាត់មានកូន ៤ នាក់រស់នៅក្នុងបន្ទុក។

ក្នុងកំឡុងមុនពេលដែលបានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិ ជាមួយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ *គ្រួសារពូ វិទ្ធិ ខុន បានជួបប្រទះបញ្ហាជាច្រើននៅក្នុងការចិញ្ចឹមមាន់ ជាពិសេសមាន់គាត់ស្មើរតែ៩០% បានឈឺ និងងាប់ ដែលតាមចំណាំកើតឡើងក្នុងចន្លោះរវាងខែកុម្ភៈដល់ខែមេសា ដែលធ្វើអោយមាន់របស់គាត់ជារៀងរាល់ឆ្នាំនៅសល់តិចតួច ចំនួនជាមធ្យម ពី ៣-៤ក្បាលប៉ុណ្ណោះ ។ ពូ វិទ្ធ ខុន បានមានប្រសាសន៍ថា ពីមុនកន្លងមកគាត់ចិញ្ចឹមមាន់ ដោយមិនមានធ្វើទ្រុងសំរាប់ដាក់ឡើយ ដោយអោយវាដេកក្បែរផ្ទះលើដើមឈើ ហើយអោយមាន់ដើរស៊ីចំណី ផឹកទឹកពាសវាលពាសកាល ដោយមិនរវីរវល់ដាក់ចំណី និងទឹកសំរាប់មាន់ទាំងនោះឡើយ ។* គាត់បាននិយាយបន្តទៀតថា គាត់មិនបានចំណាយពេលវេលា ក្នុងការថែទាំមាន់ និងបោសសំអាតកន្លែងដេកសំរាប់មាន់ឡើយ ជួនកាលខ្លះនៅតាមសំបុកមាន់ រឺកន្លែងមាន់ដេក កើតមាននូវស្រមើលដែលរំខានដល់ការរស់នៅរបស់មនុស្ស និងភាពសុខស្រួលរបស់មាន់ ជាពិសេសវាខាំកូនមាន់ ដែលទើបតែនឹងញាស់ឱ្យដំបៅប៉ោងភ្នែក ដែលធ្វើអោយកូនមាន់ខ្លះទៀតឈឺរហូតដល់ងាប់។ *លើសពីនេះទៅទៀតការចិញ្ចឹមមាន់ជួបប្រទះជម្ងឺយ៉ាងស្រួចស្រាល ដែលការព្យាបាលពុំមានប្រសិទ្ធិ-ភាពឡើយ និងធ្វើអោយមាន់ងាប់ស្មើរផុតពូជជារៀងរាល់ឆ្នាំ ដែលជាហេតុនាំឱ្យគាត់គ្មានកំលាំងចិត្តក្នុងការចិញ្ចឹម ។* ជម្ងឺទាំងនោះបង្ហាញនូវរោគសញ្ញា ដូចជា ឈឺសំកុកហៀរទឹកមាត់-ទឹកភ្នែក...និងប្រកាច់ងាប់ នៅឆ្នាំ២០០៥ គាត់បានចាក់ថ្នាំការពារជំងឺមាន់ដោយភ្នាក់ងារពេទ្យសត្វភូមិ ប៉ុន្តែធ្វើអោយមាន់គាត់ទាំងអស់ដែលបានចាក់វ៉ាក់សាំងការពារនោះបានងាប់ដោយជំងឺទាំងអស់ ដែលគាត់មានប្រសាសន៍ថាធ្វើអោយគាត់គ្មានជំនឿទៅលើការប្រើប្រាស់វ៉ាក់សាំងការពារជំងឺនេះឡើយ ។

នៅក្រោយពេលដែលអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានធ្វើការបណ្តុះបណ្តាល ស្តីពីការចិញ្ចឹមមាន់តាមគោលការណ៍ធម្មជាតិរយៈពេល៥ ថ្ងៃរួចមក ពូ វិទ្ធិ ខុន បានទទួលចំណេះដឹងទាក់នឹងការរៀបចំទ្រុង (និងធ្វើជារបងទីធ្លាជុំវិញទ្រុង), ការគ្រប់គ្រង និងថែទាំមាន់, ចំណី និងការអោយចំណី។ ដោយមានការគាំទ្រផ្តល់ជាពូជមាន់ចំនួន៨ ក្បាល (មេ៧ក្បាល និងឈ្មោល១ក្បាល) រួមជាមួយនឹងទុនសំរាប់ចូលរួមនៅ ក្នុងការសាងសង់ទ្រុងចំនួន ៣០ ០០០រៀល ពូ វិទ្ធិ ខុន បានដំណើរការចិញ្ចឹមមាន់ ដោយមានសាងសង់ទ្រុង រួមជាមួយនឹងរបងព័ទ្ធជុំវិញសំរាប់ធ្វើជាទីធ្លារបស់មាន់ផងដែរ។ *នៅក្នុងទីធ្លាទ្រុងមាន់ ពូ វិទ្ធិ ខុន បានរៀបចំកន្លែងមួយ ដែលជារណ្តៅស្តុកកាកសំណល់រុក្ខជាតិពុកផុយ រួមជាមួយចំបើងសំរាប់បង្កបង្កើតជាសត្វល្អិត សំរាប់មាន់កកាយជាចំណីបន្ថែម។ ទន្ទឹមនឹងនេះ នៅក្នុងទីធ្លាទ្រុង គាត់ក៏មានរៀបចំស្តុកទឹកស្តុកចំណី ដែលមានចំណី និងទឹកស្អាតជាប់ជាប្រចាំសំរាប់មាន់។*

# កសិកម្ម និងការអភិវឌ្ឍន៍

*ពូ វិទ្ធិ ខុន បានត្រាំវល្លិ៍បណ្តូលពេជ្រ និងគល់ស្លឹកគ្រៃ ដែលដាំនៅក្នុងភូមិដ្ឋានរបស់គាត់ សំរាប់អោយមាន់ផឹកជាប្រចាំ ដោយ២-៣ថ្ងៃ ផ្លាស់ចេញម្តង។* រីឯចំណីមាន់ ពូវិទ្ធិ ខុន បានអោយចុងអង្ករ រីស្រូវ ក្នុងមួយថ្ងៃ២-៣ ដង។ ដោយចំណាយរយៈពេលតែត្រឹម៣ខែប៉ុណ្ណោះចាប់តាំងពីការផ្តល់ពូជមាន់ដោយអង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នាពេលបច្ចុប្បន្ននេះ ពូ វិទ្ធិ ខុន មានមេមាន់ចំនួន ៤ក្បាលហើយដែលបានពង និងញាស់កូន ដែលគិតសរុបមានមាន់ចំនួន ៤៥ ក្បាលទាំងមេ និងកូនមាន់។ ពូ វិទ្ធិ ខុន បានមានប្រសាសន៍ថា ខុសប្លែកពីឆ្នាំមុនៗ ដែលនៅរៀងរាល់ខែកុម្ភៈ មីនា និងមេសា មាន់របស់គាត់តែងតែមានជំងឺ និងងាប់ជាហូរហែរ ប៉ុន្តែសំរាប់ ឆ្នាំនេះមាន់ទាំងអស់របស់គាត់មិនមានជំងឺមួយក្បាលណាឡើយ លើកលែងតែមានការរំខាន និងបំផ្លាញពីកណ្តុរ ដែលវាបានស៊ីកូនមាន់ទើបញាស់មួយចំនួនតូចប៉ុណ្ណោះ។

*មូលហេតុដែលមិនបណ្តាលអោយមាន់របស់គាត់ឈឺ និងងាប់នេះ ពូវិទ្ធិ ខុន បានធ្វើការសន្និដ្ឋានប្រកបដោយភាពជឿជាក់យ៉ាងមុតមាំថា គឺបណ្តាលមកពីគាត់បានប្រើ ប្រាស់ថ្នាំរុក្ខជាតិត្រាំទឹកអោយមានផឹក រួមជាមួយនឹងការថែទាំសំអាតទ្រុងជាប់ជាប្រចាំ។* កាលដែលមិនមានមាន់ណាឈឺ ឬងាប់ដោយសារជំងឺសូម្បីមួយក្បាល គួបផ្សំជាមួយនឹងការកើនឡើងនូវចំនួនមាន់បែបនេះ ពូ វិទ្ធិ ខុន បានប្រាប់ថាធ្វើអោយគាត់មានទឹកចិត្តកាន់តែច្រើននៅក្នុងការចិញ្ចឹម និងថែរក្សាមាន់ ព្រមទាំងបានផ្តល់នូវជំនឿយ៉ាងមុតមាំមកដល់អង្គការ សកម្មភាព ដើម្បីស្រាវជ្រាវ និង អភិវឌ្ឍន៍ ដែលបានផ្តល់នូវបច្ចេកទេសសាមញ្ញ នៅក្នុងការចិញ្ចឹមមាន់ប្រកបដោយជោគជ័យ។ *ពូ វិទ្ធ ខុន បានបង្ហាញនូវក្តីសង្ឃឹមយ៉ាងមុតមាំថា ពីពេលនេះតទៅមុខ គាត់នឹងចិញ្ចឹមមាន់ប្រកបដោយជោគជ័យ ហើយនឹងមានមាន់លក់សំរាប់យកប្រាក់ចំណូល មកជួយទំនុកបំរុងនៅក្នុងជីវភាពគ្រួសាររបស់គាត់។ នៅចុងបញ្ចប់ពូ វិទ្ធិ ខុន បានសំណូមពរ មកដល់អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និង អភិវឌ្ឍន៍ ថាឥឡូវគ្រួសារគាត់មានសាច់ (មាន់) សំរាប់ហូបហើយ តែនៅខ្វះបន្លែ ដែលគេតែងនិយមនិយាយភ្ជាប់គ្នានូវពាក្យទាំងពីរនេះថា (បន្លែ-សាច់) ហេតុនេះគាត់សូមសំណូមពរសូមអោយអង្គការផ្តល់នូវបច្ចេកទេសដាំដុះ បន្លែ (ត្រកួន ស្ពៃចង្កឹះ ផ្ទីរ...) និងផ្តល់ពូជបន្លែទាំងនោះមួយចំនួនដល់គ្រួសារគាត់ ដើម្បីបង្កើនបន្ថែមអោយកាន់តែមានភាពប្រសើរឡើង នៅក្នុងជីវភាពរបស់គ្រួសារគាត់។*

តាមរយៈករណីសិក្សាមួយខាងលើនេះ បង្ហាញអោយបានច្បាស់ថា កសិករនៅក្នុងភូមិកន្លែងរមាស ឃុំពេជ្រមុន្នី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលជាភូមិមួយក្រីក្រខ្លាំង មានការចាប់អារម្មណ៍ និងជឿជាក់ទៅលើបច្ចេកទេសចិញ្ចឹមមាន់ តាមគោលការណ៍ធម្មជាតិ ដែលកសិករមានភាពងាយស្រួល និងអាចអនុវត្តបាន ដោយមិនបាច់ចំណាយប្រាក់ច្រើនឡើយ ដែលធ្វើអោយគាត់មានភាពសប្បាយរីករាយ និងមានក្តីសង្ឃឹមឡើងវិញនៅក្នុងការធ្វើអោយការចិញ្ចឹមមាន់របស់ពួកគាត់មានភាពប្រសើរឡើង ព្រមទាំងអាចរួមចំណែកបង្កើនប្រាក់ចំណូលក្នុងគ្រួសារ សំរាប់ផ្គត់ផ្គង់ជីវភាព អោយកាន់តែមានភាពរីកចំរើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

***សូមកសិករដទៃទៀត ព្យាយាមអនុវត្តវិធីសាស្ត្រចិញ្ចឹមមាន់ តាមគោលការណ៍ធម្មជាតិ ដូចលោកពូ វិទ្ធិ ខុន។***

# ទំព័រធនធានធម្មជាតិ និងបរិស្ថាន

## បន្លែបន្ការ ដីសើម និងសំរាម : ការធានាសុវត្ថិភាពស្បៀង នៅភ្នំពេញ ប្រទេសកម្ពុជា

*(តពីលេខមុន)*

**ការស្រាវជ្រាវពីជំរើសនៃការសំអាត :** ដោយសារផលដំណាំមានជាតិគីមីបង្កគ្រោះថ្នាក់ច្រើនដល់សុខភាព គោលដៅចំបងនៃការសិក្សា គឺស្វែងរកជំរើសជាក់ស្តែងដែលល្អបំផុតសំរាប់បញ្ឈប់ការដាំបន្លែមានជាតិគីមីនេះ ។ ជំរើស៥យ៉ាងផ្សេងៗគ្នា ត្រូវបានគេវាយតំលៃ និងគណនាចំណាយសុទ្ធបន្ថែមរបស់វា ។ បន្ទាប់ពីប៉ាន់ស្មានចំណាយសរុបរួច គេប្រៀបធៀបជំរើសទាំង៥ ដើម្បីស្វែងរកវិធីសាស្ត្រដែលមានប្រសិទ្ធិភាពចំណាយល្អបំផុត (ចំណាយតិចបំផុត) ។

ជំរើសដែលអ្នកសិក្សាស្រាវជ្រាវបានលើកឡើងនោះគឺ ជំរើសផ្តល់សំណងប៉ះប៉ូវ, ជំរើសប្តូរមុខដំណាំទី២, ជំរើសប្តូរមុខដំណាំទី១, ជំរើសតាំងលំនៅថ្មីទី១ និងជំរើសតាំងលំនៅថ្មីទី២ ។ ក្នុងគ្រប់ជំរើសដែលបានធ្វើការវាយតំលៃ មានការដាក់អនុវត្តនីវិធានការបញ្ឈប់ការដាំដុះបន្លែក្នុងតំបន់ដីសើមមានជាតិពុល រីឯចំណាយសំរាប់កម្មវិធីផ្សព្វផ្សាយពត៌មានជាសាធារណៈអោយប្រជាពលរដ្ឋឈប់ទិញបន្លែមានជាតិគីមី ក៏ត្រូវបានបូកបញ្ចូលដែរ ។ ក្នុងជំរើសទី១ (មានសំណងប៉ះប៉ូវ) កសិករទាំងអស់អាចរស់នៅលើដីពួកគេដដែល ប៉ុន្តែត្រូវឈប់ដាំបន្លែសំរាប់ហូប ជាថ្នូរនឹងការឈប់ដាំដុះនេះ ពួកគេទទួលបានប្រាក់សំណងប៉ះប៉ូវ ។ ដើម្បីគណនាប្រាក់សំណងអោយបានត្រឹមត្រូវ គេត្រូវប្រៀបធៀបចំណាយប៉ាន់ស្មានពាមុខ គឺអត្រាសំណងប៉ះប៉ូវកំណត់ក្នុងគោលនយោបាយបច្ចុប្បន្ន ការវាយតំលៃពីការពេញចិត្តរបស់កសិករ ដើម្បីទទួលយកសំណង(ទិន្នន័យបានពីការធ្វើសម្ភាសន៍) និងការប៉ាន់ស្មានពីលំហូរសាច់ប្រាក់សុទ្ធរបស់កសិករ ។ ការប្រៀបធៀបនេះបង្ហាញថា តំលៃសំណងយុត្តិធម៌គឺ៤ដុល្លារក្នុងមួយម៉ែត្រការ៉េ ។

ការតាំងទីលំនៅថ្មី និងការប្តូរមុខដំណាំ :

ជំរើសពីរបន្ទាប់ទៀត គឺតំរូវអោយកសិករផ្លាស់ប្តូរកន្លែងទៅកាន់តំបន់ដីកសិកម្មថ្មី ក្នុងនេះមានដីមួយចំនួនស្ថិតនៅលើច្រាំងទន្លេមេគង្គ ។ ក្នុងជំរើសទាំងពីរនេះ កសិករមួយគ្រួសារទទួលបានដីកសិកម្មថ្មីចំនួន ០,៤ហិកតា ព្រមទាំងផ្ទះសំបែង និងហេដ្ឋារចនាសម្ព័ន្ធថែមទៀត ។ ក្នុងផែនការតាំងទីលំនៅថ្មីទី១ (ជំរើសតាំងទីលំនៅថ្មីទី១) គេប្រើប្រាស់ទឹកស្អាតសំរាប់ស្រោចស្រពដំណាំ ។ នៅក្នុងជំរើសទី២ (ជំរើសតាំងទីលំនៅថ្មីទី២) គេប្រើទឹកសំណល់ពីប្រើប្រាស់តាមគ្រួសារដែលបានឆ្លងកាត់ការច្រោះសំអាតរួចហើយ ។

ការវាយតំលៃជំរើសទាំងពីរ រួមមានកត្តាមួយចំនួនដូចជា ការវិនិយោគទុនពីដំបូងដើម្បីបង្កើតដីកសិកម្មថ្មី ចំណូលដែលកសិករអាចរកបានពីដីកសិកម្មថ្មី និងចំណូលដែលត្រូវបាត់បង់ដោយសារការផ្លាស់ប្តូរដីកសិកម្ម ។ ការចំណាយវិនិយោគដំបូងសំរាប់ជំរើសតាំងទីលំនៅថ្មីទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នា (ប្រហែល១១ ០០០ដុល្លារសំរាប់កសិករ១ គ្រួសារ) ។

ជំរើសពីរចុងក្រោយ ទាក់ទងនឹងការផ្លាស់ប្តូររបៀបប្រើប្រាស់កសិដ្ឋាន ។ ក្នុងជំរើសទី១ មានការលើកទឹកចិត្តកសិករអោយដាំដុះរុក្ខជាតិក្នុងទឹកដូចជា ត្រកួន ឈូក នៅតាមកសិដ្ឋានរបស់ខ្លួន ហើយក៏មានការលើកទឹកចិត្តអោយកសិករដាំផ្កាសំរាប់តាំងលំអក្នុងតំបន់ដីសើមបឹងជើងឯកប្រមាណ៧៥ហិកតានោះ ។ ដោយសារដីមួយចំនួនជាដីលិចទឹកជានិច្ចកាល ដូច្នេះគំរោងនេះតំរូវអោយមានការរៀបចំដីកុំអោយវាលិចទឹក ដើម្បីអាចដាំផ្កាបានពេញមួយឆ្នាំ ។ នៅក្នុងជំរើសប្តូរមុខដំណាំទី២ ក៏មានការលើកទឹកចិត្តកសិករអោយដាំរុក្ខជាតិក្នុងទឹក និងឈូកដែរ ប៉ុន្តែដីដាំផ្កាតាំងលំអ៧៥ ហិកតានោះ ត្រូវយកធ្វើកន្លែងឧស្សាហកម្មវិញ ។

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដោយលោក មឿង ស៊ីដេត និងក្រុមរបស់គាត់ ដែលមានការជួយឧបត្ថម្ភដោយកម្មវិធីបរិស្ថាន និងសេដ្ឋកិច្ចនៅអាស៊ីអគ្នេយ៍ (EEPSEA) ។ **លទ្ធផលនៃការស្រាវជ្រាវជាច្រើនទៀតអាចរកបានតាមអាសយដ្ឋាន** **www.eepsea.org** ។

# ជីវិត និងសង្គម

## អង្គការលើកលែងទោសអន្តរជាតិរិះគន់ការបណ្តេញចេញពីដីនៅក្រុងព្រះសីហនុ

***អង្គការលើកលែងទោសអន្តរ-ជាតិ ជាអង្គការសិទ្ធិមនុស្សដែលមានមូល-ដ្ឋាននៅទីក្រុងឡុង បានចេញសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃអង្គារ ថ្កោលទោសការបណ្តេញចេញកាលពីថ្ងៃទី២០ ខែមេសា នូវអ្នកភូមិរាប់រយនាក់ពីដីជំលោះនៅខណ្ឌមិត្តភាពក្រុងព្រះសីហនុ។ សេចក្តីថ្លែងការណ៍អង្គការលើកលែងទោសអន្តរជាតិនិយាយថា នគរបាលបានបណ្តេញប្រជាជន ១១៧ គ្រួសារដោយបង្ខំ...ហើយបានបំផ្លាញផ្ទះរបស់ពួកគេ។ តាមពួថា នគរបាលបានប្រើកងកំលាំងដ៏ច្រើន ក្នុងអំឡុងការបណ្តេញចេញនេះ ហើយមនុស្សជាច្រើននាក់ទាំងពីរភាគីត្រូវបានរងរបួស។***

តាមការចុះផ្សាយរបស់ព្រឹត្តិបត្រពតិមានឌឹខេមបូឌាដេលី ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៧ បានអោយដឹងបន្តទៀតថា សេចក្តីថ្លែងការណ៍របស់អង្គការលើកលែងទោសអន្តរជាតិបាននិយាយថា ការបណ្តេញចេញដោយបង្ខំ គឺជាការបំពានដ៏ធ្ងន់ធ្ងរចំពោះសិទ្ធិមនុស្សមួយចំនួន។ ក្នុងនាមជាភាគីរដ្ឋមួយនៅក្នុងអនុសញ្ញាអន្តរ-ជាតិស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធមិប្រទេសកម្ពុជាមិនត្រូវបណ្តេញនរណាម្នាក់ចេញដោយមិនមានការជូនដំណឹងគ្រប់គ្រាន់ការពិគ្រោះយោបល់ជាមុន ដំណើរការត្រឹមត្រូវនៃច្បាប់ និងការធានាអះអាងអំពីការផ្តល់លំនៅដ្ឋានគ្រប់គ្រាន់ទេ។

អង្គការលើកលែងទោសអន្តរ-ជាតិបានអះអាងថា អជ្ញាធរខកខានមិនបានដោះស្រាយកង្វល់ណាមួយក្នុងចំណោមកង្វល់ទាំងនេះទេ មុន និងក្រោយការបណ្តេញចេញ ដែលធ្វើអោយប្រជាជនរាប់រយនាក់គ្មានផ្ទះសំបែង។ កាលពីព្រឹកព្រលឹមថ្ងៃទី២០ ខែមេសា នគរបាល និងកងរាជអាវុធហត្ថប្រដាប់ដោយអាវុធប្រមាណ ១៥០នាក់ បានប៉ុនប៉ងបណ្តេញមនុស្សចេញពីដីនេះ ប៉ុន្តែត្រូវបានឆ្លើយតបដោយការតស៊ូពីអ្នកភូមិជាច្រើននាក់។ បន្ទាប់ពីមានការប្រទូស្តរាយនេះ អ្នកភូមិ១៣នាក់ ដែលរួមមានអនីតិជនម្នាក់ ត្រូវបានចាប់ខ្លួនពីបទបំផ្លាញទ្រព្យសម្បត្តិនគរបាល និងពីបទបង្ករបួសស្នាម។ ផ្ទះជាច្រើនខ្នងត្រូវបានដុតបំផ្លាញ ហើយនគរបាលបានរុះរើផ្ទះផ្សេងទៀត តែពួកគេបានបដិសេធថា មិនបានបង្កអគ្គិភ័យទេ។

ព្រឹត្តិបត្រពតិមានឌឹខេមបូឌាដេលីដដែលនេះ បានអោយដឹងទៀតថា លោកសាយ ហាក់ អភិបាលក្រុងព្រះសីហនុ បានបដិសេធការអះអាងនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ដោយលោកបាននិយាយថា អ្នកភូមិត្រូវបានគេប្រាប់ម្តងហើយ ម្តងទៀតអោយចាកចេញពីដីនេះ មុនការបណ្តេញចេញ ពីព្រោះវាជាដីរបស់ផ្សេង។

លោក សាយ ហាក់ បាននិយាយបន្តទៀតថា តាមពិតនគរបាលរបស់យើងមិនបានប្រើអំពើហឹង្សា រឺការបំពានសិទ្ធិរបស់អ្នកណាម្នាក់ហួសហេតុទេ ហើយគ្មានអ្នកភូមិណាម្នាក់ ត្រូវបាននគរបាលធ្វើអោយរងរបួសឡើយ។

លោកស្រី ណាលី ពីឡូក ប្រធានអង្គការសិទ្ធិមនុស្សក្នុងស្រុកលីកាដូ បានមានប្រសាសន៍ថា នគរបាលបានធ្វើអោយអ្នកភូមិរងរបួសអំឡុងពេលបណ្តេញចេញនេះ។ លោកស្រី មានប្រសាសន៍ទៀតថា វេជ្ជបណ្ឌិតមកពីអង្គការរបស់លោកស្រីបានទៅជួបបុរសម្នាក់ដោយផ្ទាល់ ដែលកំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យ ដើម្បីព្យាបាលរបួស ដែលបានទទួលរងនៅពេលបណ្តេញចេញនេះ និងអ្នកភូមិពីរនាក់ក្នុងចំណោមអ្នកភូមិដែលត្រូវបានចាប់ខ្លួនដែលមានស្នាមរបួសធំជាច្រើន។

**តំណាងអ្នកភូមិម្នាក់ឈ្មោះថាអាយុ៤៩ឆ្នាំ ដែលបានបដិសេធមិនប្រាប់ឈ្មោះពេញរបស់គាត់ ដោយភ័យខ្លាចចំពោះការចាប់ខ្លួននោះ បាននិយាយតាមទូរស័ព្ទថា ស្ថានភាពរបស់អ្នកភូមិផ្សេងទៀត ដែលកំពុងរស់នៅក្រោមតង់ចំងាយ ១៥០ម៉ែត្រ ពីអតីតផ្ទះរបស់ពួកគេនោះមានស្ថានភាពកាន់តែអាក្រក់ទៅៗពីមួយថ្ងៃទៅមួយថ្ងៃ ដោយកំពុងខ្វះខាតអាហារ ហើយថាកុមារ និងមនុស្សចំណាស់ភាគច្រើនកំពុងធ្លាក់ខ្លួនឈឺ។**

**ឱ សង្គមកម្ពុជា**

**និងជីវិតអ្នកក្រីក្រ-ទន់ខ្សោយ !!!**

# ជីវិត និងសង្គម

## សាលាក្តីកាត់ទោសក្រុមមេដឹកនាំខ្មែរក្រហម ឆ្ពោះទៅមុខសន្សឹមៗ

រយៈពេល៣២ឆ្នាំ បន្ទាប់ពីការស្លាប់មនុស្សអស់ប្រមាណជា១,៧លាននាក់ក្រោមរបបខ្មែរក្រហម ការរៀបចំដែលដំណើរការទៅមុខយឺតៗសំរាប់សាលាក្តីអន្តរជាតិមួយ ដែលត្រូវបានជាប់គាំងម្តងទៀតនៅដើមខែមេសា នៅពេលដែចៅក្រមបរទេសបាននិយាយថា ការបង់ថ្លៃចុះឈ្មោះសំរាប់ក្រុមមេធាវី ថ្លៃខ្ពស់ណាស់។

បន្ទាប់ពីការពន្យារពេល និងជំលោះរយៈពេលមួយទស្សវត្សរ៍ ការបង់ថ្លៃរបស់មេធាវីបានរីកទៅជាបញ្ហាធំមួយឆ្លុះបញ្ចាំងពីវិសមាមាត្ររវាងឧក្រិដ្ឋកម្មកាលពីអតីតកាល និងកង្វល់នៅបច្ចុប្បន្ននេះ។

តាមព្រឹត្តិបត្រឌឹយែមបូឌាដេលីចេញផ្សាយថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៧ បានអោយដឹងថាកាលពីសប្តាហ៍មុន គណៈមេធាវីកម្ពុជាដែលបានអះអាងការប្រមាថចំពោះអធិបតេយ្យភាពរបស់ខ្លួន បានបញ្ចុះការបង់ថ្លៃមកត្រឹម៥០០ ដុល្លារ ហើយក្រុមចៅក្រមបរទេសនៅឯសាលាក្តី បាននិយាយថាពួកគេពេញចិត្ត ដែលភាគីនីមួយៗបានចេញសេចក្តីថ្លែងការណ៍ អះអាងនូវការប្តេជ្ញារបស់ខ្លួនចំពោះតុលាការ។ ព្រឹត្តិបត្រនេះ បានសរសេរបន្តទៀតថា វាគឺជាពេលចុងក្រោយនៃឧបសគ្គធំតូច ដែលមិនអាចរាប់បានចំណោមក្រុមអ្នកចូលរួម ហើយវាទំនងជាបើកចំហផ្លូវសំរាប់កិច្ចព្រមព្រៀងមួយលើវិធាននៃនីតិវិធីរយៈពេលមួយខែចាប់ពីឥឡូវនេះ។ ប៉ុន្តែគេមិនច្បាស់ទេថា តើត្រូវប្រើពេលប៉ុន្មានទៀតមុនពេលការនាំមកនូវដីកាចោទប្រកាន់ដំបូងទេ។ ហើយបើទោះបីជាអ្វីៗទាំងអស់ដំណើរការដោយរលូនក៏ដោយ ក៏វាទំនងជាប្រើពេលច្រើនខែមុនពេលចុងចោទដំបូងត្រូវបាននាំខ្លួនទៅកាន់តុលាការ ដើម្បីប្រឈមមុខនឹងការចោទប្រកាន់ដែរ។

គួរកត់សំគាល់ផងដែរថា ចាប់តាំងពីការរៀបចំផ្នែកបច្ចេកទេសបានចាប់ផ្តើមកាលពីឆ្នាំមុនប្រហែលជាមួយភាគបីនៃថវិការយៈពេលបីឆ្នាំ សំរាប់សាលាក្តីត្រូវបានប្រើប្រាស់ដោយសារតែជម្លោះ និងការពន្យារពេល។ ពីមុនវាស៊ីពេលអស់៦ឆ្នាំ សំរាប់អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាចំណាយក្នុងការចរចារ ដែលជារឿយៗគ្មានភាពស្និទ្ធស្នាលក្នុងការទទួលបានកិច្ចព្រមព្រៀងមួយក្នុងឆ្នាំ២០០៣ សំរេចធ្វើការកាត់ទោស។ អង្គការសហប្រ-ជាជាតិបានទាមទារអោយអនុវត្តតាមស្តង់ដារអន្តរជាតិ ហើយជនកម្ពុជាបានតវ៉ាថាអធិបតេយ្យជាតិរបស់ពួកគេកំពុងត្រូវរំលោភ។ តុលាការចំរុះគ្នាដែលសំរេចបាននេះត្រូវបានរិះគន់ដោយក្រុមសិទ្ធិមនុស្សចំពោះការបង្កើតស្តង់ដារយុត្តិធម៌មួយទាបបំផុត។

រាល់ការពន្យារពេលរយៈពេលជាច្រើនឆ្នាំមកនេះ បាននាំអោយមានកង្វល់ឡើងវិញដែលថា ចុងចោទវ័យចំណាស់សំខាន់ៗប្រហែលជារស់នៅក្នុងភាពចូលនិវត្តន៍យ៉ាងស្ងៀមស្ងាត់នៅក្នុងប្រទេសកម្ពុជា និងចៀសផុតពីការកាត់ទោសទាំងស្រុង។

ប៉ុល ពត ដែលជាមេក្លោងរបបខ្មែរក្រហមបានស្លាប់ក្នុងឆ្នាំ១៩៩៨។ សុន សេន ដែលជាដៃស្តាំរបស់ប៉ុល ពត ត្រូវបានសំលាប់នៅឆ្នាំមុន។ តាម៉ុក ដែលជាបញ្ជាការយោធាខ្មែរក្រហមបានស្លាប់ក្នុងខែកក្កដាឆ្នាំកន្លងទៅ។ អ្នកនៅរស់សំខាន់ៗ គឺ នួន ជា, ខៀវ សំផន និង អៀង សារី ត្រូវបានគេរាយការណ៍ថា ស្ថិតក្នុងសុខភាពទ្រុឌទ្រោម។ មានតែមនុស្សសំខាន់ម្នាក់ប៉ុណ្ណោះដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ គឺកាំង ហ្គេចអ៊ាវ ប្រធានពន្ធនាគារធ្វើទារុណកម្មទួលស្លែង។

ថ្វីបើមានបញ្ហានេះក៏ដោយ ពួកចៅក្រម និងព្រះរាជអជ្ញាបានដោះស្រាយវិធាននៃនីតិវិធីជាង១០០ ដែលពេលខ្លះមាន ភាពស្មុគ្រស្មាញដោយឆ្លងកាត់ឧបសគ្គនៃប្រព័ន្ធច្បាប់ ភាសា និងវប្បធម៌។ ក្រោមប្រព័ន្ធភាគច្រើនបំផុតដែលមានភាពស្មុគ្រស្មាញមួយ ជនកម្ពុជាមានចំនួនលើសអ្នកចូលរួមបរទេស។ ប៉ុន្តែជនបរទេសមានសិទ្ធិវ៉េតូសេចក្តីសំរេចណាមួយ។

**យើងមានសង្ឃឹមថា សូមកុំអោយមានការបង្កជាឧបសគ្គអ្វីបន្តទៀត ហើយសូមអោយភាគីទាំងពីរ បំពេញការ-ងារប្រកបដោយសុឆន្ទៈពិត និងយុត្តិធម៌។**



# ទំព័រចុងក្រោយសំរាប់អ្នក

**សូមបោះឆ្នោតជូនប្រាសាទអង្គរវត្ត ជាអច្ឆរិយទាំង៧ក្នុងពិភពលោក**

| |
|---|
| **LE CRI D’APPEL DE « ANGKOR WAT »** |
| **សំរែកប្រាសាទអង្គរវត្ត** |
| **THE CRY OF CALL OF « ANGKOR WAT »** |

**<< EMMENEZ-MOI AU « 7 MERVEILLES DU MONDE »;
VOUS SEREZ TRES NOBLEMENT HONORE >>**

**<<សូមមេត្តាជួយនាំអោយខ្ញុំបានដល់ ”អច្ឆរិយវិមានពិភពលោកទាំង៧”**

**លោកអ្នកនាង នឹងមានមហាកិត្តិយសដ៏ឧត្តុង្គឧត្តម >>**

**<< TAKE ME ALONG TO THE « 7 WONDERS OF THE WORLD »;**

***YOU WILL VERY NOBLEMENT BE HONOURED >>***

******

**- Ensemble, aidons-le ; soutenons-le ; emmenons-le jusqu’au
« 7 Merveilles du Monde » et donc, mobilisons-nous, s’il vous plait, merci.**

**- ទាំងអស់គ្នា ខំជួយ ខំគាំទ្រ ខំនាំប្រាសាទយើង អោយបានដល់**

**”អច្ឆរិយវិមានពិភពលោកទាំង៧”ៗ ពួដូច្នេះយើងត្រូវកេណ្ឌកម្លាំងគ្នា, សូមអរគុណ។**

**- Together, let us help it, let us support it, it along until the « 7 wonders
of the world », and we mobilize take, please, thank you.**

## <u>Vote</u>: <u>www.new7wonders.com</u>

**Comité de Soutien « ANGKOR Wat » à l’élection des « 7 Merveilles du Monde »**
**<u>Email</u>: haing-kheang.lim@wanadoo.fr**